# វីរុសកូរ៉ូណា 2019 ថ្មី (COVID-19)

អ្វីដែលលោកអ្នកចាំបាច់ត្រូវយល់ដឹង

LONG BEACH HEALTH & HUMAN SERVICES

WWW.LONGBEACH.GOV/NOVELCORONAVIRUS

## តើអ្វីជាវីរុសកូរ៉ូណា 2019 ថ្មី (COVID-19)?

វីរុសកូរ៉ូណា 2019 ថ្មី (COVID-19) គឺជាវីរុសផ្លូវដង្ហើម ដែលត្រូវបានកំណត់រកឃើញដំបូងនៅខែធ្នូ ឆ្នាំ 2019 ក្នុងទីក្រុងវូហាន ខេត្តហ៊ូប៉ី ប្រទេសចិន ។ វីរុសនេះអាចមានប្រភពដើមចេញពីសត្វ ប៉ុន្តែ នាពេលឥឡូវនេះ វាកំពុងឆ្លងពីមនុស្សទៅមនុស្ស ។

នាយកដ្ឋានសុខាភិបាលឡុងប៊ិច កំពុងធ្វើការតាមដានត្រួតពិនិត្យ ដាក់យកចិត្តទុកដាក់ លើសភាពការណ៍ ហើយ ចាត់វិធានការនានា ដើម្បីរក្សាឱ្យឡុងប៊ិច មានសុវត្ថិភាព ។

## តើវាឆ្លងតាមរបៀបណាខ្លះ ?

- ទំនាក់ទំនងជិតស្និទ លក្ខណៈ បុគ្គល ដូចជាការប៉ះកាន់ និងការចាប់ដៃ
- តំណក់ទឹកមាត់ ពេលក្អក និងកណ្តាស់
- ការប៉ះ ភ្នែក ច្រមុះ និង មាត់ របស់លោកអ្នក ដោយដៃមិន បានលាងសម្អាត

## តើមានការកំណត់រករោគសញ្ញា ដោយរបៀបណាដែរ?

អ្នកផ្តល់សេវាថែទាំសុខភាព នឹងវាយតម្លៃ អ្នកជំងឺ ហើយ ធ្វើការពិគ្រោះជាមួយ នាយកដ្ឋានសុខាភិបាល ថាតើត្រូវធ្វើតេស្ត ឬអត់នោះ ។

## តើមានការព្យាបាល បែបណាខ្លះ ?

មនុស្សភាគច្រើន នឹងជាសះស្បើយ ដោយខ្លួនឯង ។ គ្មានការព្យាបាល ជាក់លាក់សម្រាប់ ការឆ្លងវីរុសកូរ៉ូណា ថ្មី នេះនោះទេ ។

## តើមានរោគសញ្ញា អ្វីខ្លះ ?

រោគសញ្ញា ដែលមានរាយការណ៍ នាពេលបច្ចុប្បន្ននេះ រួមមាន ជំងឺផ្លូវដង្ហើម ពីកម្រិតស្រាល ដល់កម្រិតធ្ងន់ធ្ងរ ដោយមាន គ្រុនក្តៅ ក្អក និង ពិបាកដកដង្ហើម ។










## តើខ្ញុំប្រឈមនឹងហានិភ័យ ដែរឬទេ ?



ខ្ញុំបានធ្វើដំណើរ ទៅប្រទេសចិន ក្នុងរយៈពេល ពីរសប្តាហ៍ ចុងក្រោយនេះ ។

ឬ



ខ្ញុំបានមានទំនាក់ទំនង យ៉ាងជិតស្និតជាមួយអ្នក ដែលមានផ្ទុកវីរុសវីរុសកូរ៉ូណា 2019 ថ្មី (COVID-19) ។

\+



ខ្ញុំធ្លាក់ខ្លួនឈឺ ដោយមាន គ្រុនក្តៅ និង ក្អក ឬ ដកដង្ហើមខ្លីៗ ។

=



**សូមទំនាក់ទំនង ទៅអ្នកផ្តល់សេវាថែទាំសុខភាព របស់លោកអ្នក ដើម្បីកំណត់ថាតើ ត្រូវធ្វើតេស្ត ឬអត់នោះ ។**

## តើខ្ញុំបង្ការការរីករាលដាលវីរុសកូរ៉ូណា 2019 ថ្មី (COVID-19) បានដោយរបៀបណាដែរ ?

- សូមលាងសម្អាតដៃរបស់លោកអ្នក ដោយសាប៊ូ និងទឹក ក្នុងរយៈពេលយ៉ាងហោចណាស់ 20 វិនាទី ឱ្យបានញឹកញាប់ ។
- សូមកុំប៉ះ ភ្នែក ច្រមុះ និងមាត់ របស់លោកអ្នក ដោយដៃ ដែលមិនបានលាងសម្អាត ឱ្យសោះ ។
- សូមជៀសវាងកុំនៅជិត អ្នកមានជំងឺ ។
- គ្រប មាត់ ឬច្រមុះ របស់លោកអ្នក ដោយក្រដាស់ជូតមាត់ ពេលក្អក ឬកណ្តាស់ ហើយ បោះចោលក្រដាស់ជូតមាត់នោះ ទៅក្នុងធុងសម្រាម ។
- សូមនៅក្នុងផ្ទះ ប្រសិនបើលោកអ្នកឈឺ ។
- សូមសម្អាត និង កម្ចាត់មេរោគ ឱ្យបានញឹកញាប់ ចំពោះ វត្ថុ និងផ្ទៃរាបដែលមានការប៉ះកាន់នោះ ។